**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ......៨៧០ បទ.......... ថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៥

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ដំណើរការរៀបចំកិច្ចការអភិបាលកិច្ចបញ្ញាសិប្បនិម្មិត

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) សូមជូនដំណឹងដល់សាធារណជននិងស្ថាប័នពាក់ព័ន្ធអំពីវឌ្ឍនភាពសកម្មភាពការងារសំខាន់ៗមួយចំនួនដែល **ក.ប.ទ.** បាននិងកំពុងអនុវត្តដើម្បីត្រៀមខ្លួនក្នុងនាមជាក្រសួងជំនាញទទួលបន្ទុកវិស័យឌីជីថល សម្រាប់ការធ្វើអភិបាលកិច្ចបញ្ញាសិប្បនិម្មិតនិងបច្ចេកវិទ្យាឌីជីថលឈានមុខ ដូចខាងក្រោម៖

## ១. សុខដុមនីយកម្មអភិបាលកិច្ចនិងសីលធម៌បញ្ញាសិប្បនិម្មិតក្នុងតំបន់អាស៊ាន

ក្នុងនាមជាតំណាងកម្ពុជាក្នុងយន្តការកិច្ចប្រជុំរដ្ឋមន្ត្រីឌីជីថលអាស៊ាន (ADGMIN) កិច្ចប្រជុំឧត្តមមន្ត្រីឌីជីថលអាស៊ាន (ADGSOM) និងក្រុមការងារអាស៊ានស្តីពីអភិបាលកិច្ចបញ្ញាសិប្បនិម្មិត (WG-AI) **ក.ប.ទ.** បានចូលរួមរៀបចំ និងអនុម័តឯកសារចំនួន ៣ ដើម្បីធ្វើសុខដុមនីយកម្មអតិក្រមនៃអភិបាលកិច្ចនិងសីលធម៌បញ្ញាសិប្បនិម្មិតនៅក្នុងតំបន់អាស៊ាន ព្រមទាំងមានផែនការការងារបន្ត ដូចខាងក្រោម៖

| **សកម្មភាពកន្លងមក** | | |
|---|---|---|
| ១ | ចូលរួមអនុម័ត "មគ្គុទេសក៍អាស៊ានស្តីពីអភិបាលកិច្ចនិងសីលធម៌បញ្ញាសិប្បនិម្មិត" (ASEAN Guide on AI Governance and Ethics) ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីឌីជីថលអាស៊ាន | ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤ |
| ២ | ចូលរួមសិក្ខាសាលារៀបចំ "ផែនទីបង្ហាញផ្លូវអាស៊ានស្តីពីបញ្ញាសិប្បនិម្មិតប្រកបដោយការទទួលខុសត្រូវ" (ASEAN Responsible Artificial Intelligence Roadmap) ជាមួយបណ្តាសមាជិក WG-AI មកពីប្រទេសអាស៊ាន និង តំណាងសហរដ្ឋអាមេរិក | ថ្ងៃទី៤-៥ខែមិថុនាឆ្នាំ២០២៤ |
| ៣ | រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើ "សេចក្តីព្រាងមគ្គុទេសក៍បន្ថែមអាស៊ានស្តីពីអភិបាលកិច្ចនិងសីលធម៌បញ្ញាសិប្បនិម្មិត សម្រាប់បញ្ញាសិប្បនិម្មិតបង្កើតមាតិកា" (Expanded ASEAN Guide on AI Governance and Ethics for Generative AI) ជាមួយក្រសួង ស្ថាប័ន វិស័យឯកជន និងស្ថាប័នដៃគូនៅកម្ពុជា | ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ |
| ៤ | ចូលរួមអនុម័ត ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីឌីជីថលអាស៊ាន (លើកទី៥)៖<br>១- មគ្គុទេសក៍បន្ថែមអាស៊ានស្តីពីអភិបាលកិច្ចនិងសីលធម៌បញ្ញាសិប្បនិម្មិតសម្រាប់បញ្ញាសិប្បនិម្មិតបង្កើតមាតិកា<br>២- ផែនទីបង្ហាញផ្លូវអាស៊ានស្តីពីបញ្ញាសិប្បនិម្មិតប្រកបដោយការទទួលខុសត្រូវ | ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥ |

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210
123 023 724 810
www.mptc.gov.kh

| ជំហានបន្ទាប់ | | |
|---|---|---|
| ១ | បកប្រែ មគ្គុទេសក៍អាស៊ានស្តីពីអភិបាលកិច្ចនិងសីលធម៌បញ្ញាសិប្បនិម្មិត | បានបញ្ចប់, កំពុងពិនិត្យវាក្យសព្ទបច្ចេកទេស |
| ២ | បកប្រែ៖<br>១- មគ្គុទេសក៍បន្ថែមអាស៊ានស្តីពីអភិបាលកិច្ចនិងសីលធម៌បញ្ញាសិប្បនិម្មិតសម្រាប់បញ្ញាសិប្បនិម្មិតបង្កើតមាតិកា<br>២- ផែនទីបង្ហាញផ្លូវអាស៊ានស្តីពីបញ្ញាសិប្បនិម្មិតប្រកបដោយការទទួលខុសត្រូវ | គ្រោងបញ្ចប់ ថ្ងៃទី៣០ខែឧសភាឆ្នាំ២០២៥ |
| ៣ | រៀបចំសទ្ទានុក្រមវាក្យសព្ទបច្ចេកទេសបញ្ញាសិប្បនិម្មិត | ចាប់ផ្តើមពីចុងខែមេសា ឆ្នាំ២០២៥ តទៅ |
| ៤ | រៀបចំ "គោលការណ៍ណែនាំស្តីពីអភិបាលកិច្ចនិងសីលធម៌បញ្ញាសិប្បនិម្មិតកម្ពុជា" | គ្រោងបញ្ចប់សេចក្តីព្រាងបឋម ថ្ងៃទី៣០ខែឧសភាឆ្នាំ២០២៥ |

## ២. ការវាយតម្លៃភាពរួចរាល់ផ្នែកសីលធម៌បញ្ញាសិប្បនិម្មិតនៅកម្ពុជា

ដោយមានការគាំទ្រពី **គ.ប.ឌ.** បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (**ប.ប.ឌ.**) បានសហការជាមួយអង្គការយូណេស្កូ ក្នុងការវាយតម្លៃភាពរួចរាល់ផ្នែកសីលធម៌បញ្ញាសិប្បនិម្មិតនៅកម្ពុជា តាមវិធីសាស្ត្រវាយតម្លៃភាពរួចរាល់ផ្នែកសីលធម៌បញ្ញាសិប្បនិម្មិត (AI Ethics Readiness Assessment Methodology – RAM) ដែលជាវិធីសាស្ត្រកម្រិតសាកលដំបូងគេ មានលក្ខណៈជាប្រព័ន្ធ ក្នុងការវាយតម្លៃភាពរួចរាល់របស់ប្រទេសមួយលើទិដ្ឋភាពចំនួន៥ គឺ (១) ច្បាប់ (២) សង្គមនិងវប្បធម៌ (៣) វិទ្យាសាស្ត្រនិងអប់រំ (៤) សេដ្ឋកិច្ច និង (៥) បច្ចេកទេស។ **ប.ប.ឌ.** និង យូណេស្កូ បានអនុវត្តសកម្មភាពនិងមានផែនការបន្តដូចខាងក្រោម៖

| សកម្មភាពកន្លងមក | | |
|---|---|---|
| ១ | ចូលរួមវេទិកាសកលស្តីពីសីលធម៌បញ្ញាសិប្បនិម្មិត (Global Forum on the Ethics of AI) រៀបចំដោយយូណេស្កូ | ថ្ងៃទី៥-៦ខែកុម្ភៈឆ្នាំ២០២៤ |
| ២ | ប្រកាសដាក់ឱ្យដំណើរការការវាយតម្លៃភាពរួចរាល់ផ្នែកសីលធម៌បញ្ញាសិប្បនិម្មិតនៅកម្ពុជា | ថ្ងៃទី១២ខែវិច្ឆិកាឆ្នាំ២០២៤ |
| ៣ | ប្រមូលទិន្នន័យនិងជួបប្រជុំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធសំខាន់ៗ | ខែវិច្ឆិកា ឆ្នាំ២០២៤ ដល់ ខែកុម្ភៈ ឆ្នាំ២០២៥ |
| ៤ | រៀបចំសិក្ខាសាលាពិនិត្យនិងផ្តល់សុពលភាពលើរបាយការណ៍និងអនុសាសន៍ | ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៥ |
| **ជំហានបន្ទាប់** | | |
| ១ | ពិនិត្យកែសម្រួលនិងរៀបចំរបាយការណ៍លទ្ធផលសេចក្តីព្រាងចុងក្រោយ | គ្រោងនឹងបញ្ចប់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥ |
| ២ | ដាក់ជូនគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលពិនិត្យនិងផ្តល់អនុសាសន៍ | ខែឧសភា ឆ្នាំ២០២៥ |
| ៣ | ដាក់ជូនក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមកិច្ចឌីជីថល | ខែឧសភា ឆ្នាំ២០២៥ |
| ៤ | ប្រកាសដាក់ឱ្យប្រើប្រាស់និងផ្សព្វផ្សាយជាផ្លូវការរបាយការណ៍ស្តីពីការវាយតម្លៃភាពរួចរាល់ផ្នែកសីលធម៌បញ្ញាសិប្បនិម្មិតនៅកម្ពុជា (ក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីយុទ្ធសាស្ត្រ ជាតិស្តីពីបញ្ញាសិប្បនិម្មិត) | ខែមិថុនា ឆ្នាំ២០២៥ |

ឲ

## ៣. ការរៀបចំ "យុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត"

បន្ទាប់ពីទទួលបានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមរយៈលិខិតលេខ៣១៦ សជណ.អស ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤ **ក.ប.ឌ.** បានបង្កើតក្រុមការងារស្រាវជ្រាវនិងអភិវឌ្ឍបញ្ញាសិប្បនិម្មិតនិងវិទ្យាសាស្ត្រទិន្នន័យ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៤។ ក្រុមការងារបច្ចេកទេសនេះបានស្រាវជ្រាវនិងរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិតអស់រយៈពេលជិត១ឆ្នាំ ដែលឆ្លងកាត់កិច្ចប្រជុំផ្ទៃក្នុង១២លើក រហូតបានចេញជាសេចក្តីព្រាងបឋមនាខែកុម្ភៈ ឆ្នាំ២០២៥។ **ក.ប.ឌ.** បានទទួលការគាំទ្រពីគណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (UN-ESCAP) ក្នុងការពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិតរហូតដល់ចប់។ ក្រុមការងារដែលរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិតបានធ្វើសកម្មភាពនិងមានផែនការការងារបន្តដូចខាងក្រោម៖

| **សកម្មភាពកន្លងមក** | | |
|---|---|---|
| ១ | ស្រាវជ្រាវនិងកាត់តែងសេចក្តីព្រាងបឋម | ខែមេសា ឆ្នាំ២០២៤ ដល់ ខែកុម្ភៈ ឆ្នាំ២០២៥ |
| ២ | កិច្ចប្រជុំពិគ្រោះយោបល់ជាមួយបណ្តាញអ្នកបច្ចេកទេសឌីជីថលនៃ UN-ESCAP | ថ្ងៃទី១៩ខែកុម្ភៈឆ្នាំ២០២៥ ថ្ងៃទី១៨ខែមីនាឆ្នាំ២០២៥ |
| ៣ | សេចក្តីព្រាង "យុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត" កំណែទី២ | ខែមីនា ឆ្នាំ២០២៥ |
| ៤ | សិក្ខាសាលាពិនិត្យស៊ីជម្រៅលើសេចក្តីព្រាង "យុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត" | ថ្ងៃទី៧-៨ខែមេសាឆ្នាំ២០២៥ |
| **ជំហានបន្ទាប់** | | |
| ១ | បណ្តុះបណ្តាលជនបង្គោលបច្ចេកទេសផ្នែកបញ្ញាសិប្បនិម្មិតពីក្រសួង ស្ថាប័ន | ខែឧសភា ឆ្នាំ២០២៥ |
| ២ | ពិគ្រោះយោបល់ទ្វេភាគី/ពហុភាគីជាមួយក្រសួង ស្ថាប័ន | ខែឧសភា ឆ្នាំ២០២៥ |
| ៣ | រៀបចំសិក្ខាសាលាថ្នាក់ជាតិ | ខែមិថុនា ឆ្នាំ២០២៥ |
| ៤ | ដាក់ជូនគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលពិនិត្យនិងអនុម័ត | ខែមិថុនា ឆ្នាំ២០២៥ |
| ៥ | បញ្ចប់សេចក្តីព្រាងចុងក្រោយនិងបកប្រែ | ខែមិថុនា-កក្កដា ឆ្នាំ២០២៥ |
| ៦ | ដាក់ឆ្លងក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថលពិនិត្យនិងសម្រេច | ខែសីហា ឆ្នាំ២០២៥ |

## ៤. ការរៀបចំ "ក្របខណ្ឌជាតិសម្រាប់អភិបាលកិច្ចបញ្ញាសិប្បនិម្មិត"

ដើម្បីឱ្យមានគុណភាពរវាងនិយ័តកម្មនិងនវានុវត្តន៍បញ្ញាសិប្បនិម្មិត **ក.ប.ឌ.** បាននិងកំពុងរៀបចំសេចក្តីព្រាងក្របខណ្ឌជាតិសម្រាប់អភិបាលកិច្ចបញ្ញាសិប្បនិម្មិត ដែលមានលក្ខណៈជាប្រព័ន្ធ ស្របតាមនិន្នាការសកល និងបរិការណ៍របស់កម្ពុជា។ **ក.ប.ឌ.** បានអនុវត្តសកម្មភាពនិងមានផែនការការងារបន្តដូចខាងក្រោម៖

| **សកម្មភាពកន្លងមក** | | |
|---|---|---|
| ១ | សិក្សាស្រាវជ្រាវក្របខណ្ឌអភិបាលកិច្ចរបស់បណ្តាប្រទេសនានា | ខែវិច្ឆិកា ឆ្នាំ២០២៤ ដល់ ខែកុម្ភៈ ឆ្នាំ២០២៥ |
| ២ | រៀបចំឯកសារទស្សនាទាន | ខែកុម្ភៈ ឆ្នាំ២០២៥ |
| ៣ | កាត់តែងសេចក្តីព្រាងបឋម | ខែមីនា ឆ្នាំ២០២៥ |

| ជំហានបន្ទាប់ | | |
|---|---|---|
| ១ | បញ្ចប់ការតាក់តែងសេចក្តីព្រាងបឋម | ខែមិថុនា ឆ្នាំ២០២៥ |
| ២ | កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកជំនាញជាតិនិងអន្តរជាតិ | ខែកក្កដា-ខែសីហាឆ្នាំ២០២៥ |
| ៣ | ពិគ្រោះយោបល់ទ្វេភាគី/ពហុភាគីជាមួយក្រសួង ស្ថាប័ន | ខែកញ្ញា ឆ្នាំ២០២៥ |
| ៤ | រៀបចំសិក្ខាសាលាថ្នាក់ជាតិ | ខែតុលា ឆ្នាំ២០២៥ |
| ៥ | ដាក់ជូនកិច្ចប្រជុំគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលពិនិត្យនិងអនុម័ត | ខែវិច្ឆិកា ឆ្នាំ២០២៥ |
| ៦ | បញ្ចប់សេចក្តីព្រាងចុងក្រោយនិងបកប្រែ | ខែវិច្ឆិកា- ខែធ្នូ ឆ្នាំ២០២៥ |
| ៧ | ដាក់ឆ្លងក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថលពិនិត្យនិងសម្រេច | ខែធ្នូ ឆ្នាំ២០២៥ |

## ៥. យុទ្ធសាស្ត្រជំរុញបញ្ញាសិប្បនិម្មិតកម្រិតវិស័យ

ក្រៅពីកិច្ចការកម្រិតជាតិ **ក.ប.ឌ.** បាននិងកំពុងរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ញាសិប្បនិម្មិត **ក.ប.ឌ.** ដើម្បីជំរុញការចាប់យកបញ្ញាសិប្បនិម្មិតក្នុងក្រសួង និងក្នុងវិស័យនៅក្រោមការគ្រប់គ្រងរបស់ក្រសួង។ **ក.ប.ឌ.** បានអនុវត្តសកម្មភាពនិងមានផែនការការងារបន្តដូចខាងក្រោម៖

| សកម្មភាពកន្លងមក | | |
|---|---|---|
| ១ | សិក្សាវិភាគស្ថានភាពបច្ចុប្បន្ននិងតម្រូវការ | ខែសីហា-ធ្នូ ២០២៤ |
| ២ | កិច្ចប្រជុំលើកទី១ ស្តីពីការរៀបចំរបាយការណ៍ស្រាវជ្រាវស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ញាសិប្បនិម្មិត **ក.ប.ឌ.** ( Kick-off meeting ) | ថ្ងៃទី២៩ខែសីហាឆ្នាំ២០២៤ |
| ៣ | កិច្ចប្រជុំបច្ចេកទេសប្រមូលធាតុចូលសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ញាសិប្បនិម្មិត **ក.ប.ឌ.** | ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០២៤ |
| ៤ | កិច្ចប្រជុំស្តីពីលទ្ធផលបឋមនៃការរៀបចំរបាយការណ៍ស្រាវជ្រាវស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ញាសិប្បនិម្មិត **ក.ប.ឌ.** ( Interim report meeting ) | ថ្ងៃទី១១ខែវិច្ឆិកាឆ្នាំ២០២៤ |
| ៥ | កិច្ចប្រជុំបច្ចេកទេសលើលទ្ធផលស្រាវជ្រាវស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ញាសិប្បនិម្មិត **ក.ប.ឌ.** | ថ្ងៃទី១៥ខែវិច្ឆិកាឆ្នាំ២០២៤ |
| ៦ | វេទិកា "បញ្ញាសិប្បនិម្មិតកម្ពុជា" ក្រោមប្រធានបទ "ស្វែងយល់អំពីនវានុវត្តន៍បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងកាលានុវត្តភាពសម្រាប់កម្ពុជានាពេលអនាគត" | ថ្ងៃទី២៥ខែវិច្ឆិកាឆ្នាំ២០២៤ |
| ៧ | កិច្ចប្រជុំលើរបាយការណ៍ចុងក្រោយស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ញាសិប្បនិម្មិត**ក.ប.ឌ.** | ថ្ងៃទី១៩ខែធ្នូ ឆ្នាំ២០២៤ |
| ៨ | កិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ញាសិប្បនិម្មិត **ក.ប.ឌ.** | ថ្ងៃទី៤និងទី១១ខែមេសា ឆ្នាំ២០២៥ |

| ជំហានបន្ទាប់ | | |
|---|---|---|
| ១ | សិក្ខាសាលាពិគ្រោះយោបល់ផ្ទៃក្នុង **ក.ប.ទ.** ស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ញាសិប្បនិម្មិត **ក.ប.ទ.** | ថ្ងៃទី៩ខែឧសភាឆ្នាំ២០២៥ |
| ២ | សិក្ខាសាលាពិគ្រោះយោបល់សាធារណៈជាមួយវិស័យឯកជន និងគ្រឹះស្ថានអប់រំស្រាវជ្រាវ ស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍បញ្ញាសិប្បនិម្មិត **ក.ប.ទ.** | ថ្ងៃទី១៦ខែឧសភាឆ្នាំ២០២៥ |

សាធារណជននិងស្ថាប័នដែលមានបំណងចូលរួមក្នុងសកម្មភាពអភិបាលកិច្ចណាមួយខាងលើ អាចបំពេញទម្រង់បែបបទតាមរយៈតំណភ្ជាប់សុវត្ថិភាព go.gov.kh/mptc/o1sz1j ឬ ស្កេន កូដឃ្យូ.អ ដូចមានភ្ជាប់ជូនខាងក្រោម។

អាស្រ័យហេតុនេះ សូម សាធារណជន និងស្ថាប័នពាក់ព័ន្ធ មេត្តាជ្រាបជាព័ត៌មាននិងអញ្ជើញចូលរួមក្នុងសកម្មភាពពាក់ព័ន្ធទៅតាមជំនាញនិងលទ្ធភាព។

**សូមស្កេន កូដឃ្យូ.អ**

https://go.gov.kh/mptc/o1sz1j

GO.gov.KH